-បានឃើញច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ឆ្នាំ ១៩៩៧

-បានឃើញច្បាប់ស្តីពីការបង្កើតថវិកាពិសេសរបស់រដ្ឋជាតិ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣៩៨/០៥ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ ១៩៩៨

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១៨.០០០ លានរៀល (ដប់ប្រាំបីពាន់លានរៀល) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់ចែងជាក់ មកជំពូក ១៣ ( ចំណាយសកម្មភាពនៃកម្មវិធី ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ សំរាប់ទូទាត់សោហ៊ុយការចំណាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

**មាត្រា ៣ .-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ១៩៩៨ តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៨ ខែឧសភា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៦ អនក្រ . បក**

**ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញា**

**កងរាជអាវុធហត្ថ**

* * * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-យោងតាមអនុក្រឹត្យ លេខ ០៩ អ.ន.ក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីឯកសណ្ឋាន និង ផ្លាកសញ្ញា កងទ័ពជាតិកម្ពុជា

-យោងតាមអនុក្រឹត្យលេខ ១៨ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីឯកសណ្ឋាន បច្ចេកទេស និងទង់ជ័យ កងយោធពលខេមរភូមិន្ទ

-យោងតាមអនុក្រឹត្យលេខ ១៩ អ.ន.ក្រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៤ ស្តីពីការកែតម្រូវ និងបំពេញបន្ថែមអនុក្រឹត្យលេខ ០៩ អ.ន.ក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៣ របស់រាជរដ្ឋាភិបាលបណ្តោះអាសន្ន

-បានឃើញអនុក្រឹត្យលេខ ៧៧ អ.ន.ក្រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណើរបស់ក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

**សំរេច**

មាត្រា ១ ._ ត្រូវបានរៀបចំ ឯកសណ្ឋានកងរាជអាវុធហត្ថ ដែលមានដូចខាងក្រោម ៖

<u>**រូបភាព ម៉ូត និងប្រភេទឯកសណ្ឋាន**</u>

ក_ **ឯកសណ្ឋានថ្នាក់ ឧត្តមសេនីយ៍ :**

**១- ឯកសណ្ឋានធំលេខ ១ និងលេខ ២ :** ដូចឯកសណ្ឋានជើងគោក នៃកងយោធពលខេមរភូមិន្ទទាំងអស់ ដោយឡែក សក្តិសំរាប់ជាមួយឯកសណ្ឋានធំលេខ ២ ផ្ទៃក្រឡុងពណ៌ខៀវ ។

**២- ឯកសណ្ឋានលេខ ៣ : ( សាហារីយ៉ែន )** សំរាប់ពាក់ក្នុងពិធីបុណ្យជាតិ បើក បិទ វគ្គរៀនសូត្រ ពិធីការធម្មតាអាវក្រៅពាក់ពេលព្រឹក ពណ៌ប្រផេះ ខ្សែរ៉ូបព្រះសង្ហារ ពណ៌មាស និងអាវ ពណ៌ក្រែម ។

-ឯកសណ្ឋានធំលេខ ៣ នេះ មានម៉ូត ដូចឯកសណ្ឋានលេខ ៣ របស់កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ប៉ុន្តែត្រូវដាក់ការលើកកអាវមានរាងស្លឹកពោធិ ។

-ស្បែកជើង និងស្រោមជើង ( ដូចឯកសណ្ឋានធំលេខ២ )

-មួកកាស្កេត ពណ៌ប្រផេះ ជើងមួក ពណ៌ខៀវទឹកប៊ិច

-ចំពោះយុទ្ធនារី អាវ កបើក រ៉ូបចង្កេះ តាមរាងនារី សំពត់ស្ទើរក្រោមជង្គង់

**៣- ឯកសណ្ឋានការងារ :** សំរាប់ធ្វើការងារក្នុងការិយាល័យ ក្នុងបន្ទាយនិងទាក់ទងស្ថាប័ននានា និង ទីសាធារណៈ ។

www.pheakdeylaw.com

<u>រូបភាព និង ម៉ូត</u>

-អាវដៃខ្លីក្រណាត់តេហ្គាល ពណ៌ប្រផេះ កខុប ប៉ូតស្មា កាត់ត្រង់វែង ហោប៉ៅពីរដេរប៉ះចំកណ្ដាលដេរបត់ផ្ដតមួយ មានគំរបរាងស្លឹកពោធិ ឡេវតូច ពណ៌ប្រផេះ ។

-ខោឡេវរូត ក្រណាត់តេហ្គាល ពណ៌ភ្លោអ៊ី ម៉ូតដូចឯកសណ្ឋានធំលេខ ៣

-មួកបេរ៉េ ក្រណាត់កាំម្ទី ពណ៌ខៀវ ទឹកប៊ិច ពាក់បញ្ឆិតខាងឆ្វេង រូបព្រះសង្ការខាងស្ដាំ

-ចំពោះនារី អាវដូចបុរស សំពត់ហ្សីប ក្រោមជង្គង់ ឬ ខោឡេវរូត ចំហៀង

៤-<u>ឯកសណ្ឋានជំនាញ</u> : សំរាប់ពាក់ក្នុងពេលប្រតិបត្តិការ ហ្វឹកហ្វឺន និងបេសកកម្មការងារជំនាញ ឯកសណ្ឋានក្រណាត់កាគី ពណ៌ពុតអ៊ី កបើក ថ្នេរខុប ប្រើឡេវតូច ( ពាក់មួកស៊ីកាស ឬបេរ៉េ ។

-ឯលេកសណ្ឋាននេះមានរូបភាព និង ម៉ូត ដូចឯកសណ្ឋានការងារ ខុសត្រង់អាវដៃវែង កបើក ថ្នេរខុប មានឡេវបង្កប់នៅចុងដៃអាវ រង្វង់ដៃបំពង់ មានឡេវក្រវាត់ កាត់ត្រង់វែង ដាក់ក្នុងខោ ។

-ខោឡេវរូតជើងវែង ចង្កេះត ថ្នេរខុប ហោប៉ៅខាងក្រោយពីរដេរបង្កប់ មានគំរបរាងស្លឹកពោធិ ហោប៉ៅពីរនៅចំហៀង តាមថ្នេរខោ ដេរបង្កប់ មាត់បញ្ឆិត ប៉ានជង្គង់ ជើងខោចងខ្សែ ។

-ស្បែកជើង កវែង ធ្វើពីស្បែកពណ៌ខ្មៅ ចងខ្សែ ឬ រូត និងស្រោមជើង ពណ៌ពុតអ៊ី ។

៥-<u>ឯកសណ្ឋានប្រយុទ្ធ</u> : ឯកសណ្ឋានប្រយុទ្ធដូចទ័ពជើងគោក ផែនកលាក់ពណ៌ផែនដីភូមិន្ទ ទាំងអស់ ដូចជា ខោ អាវ ស្បែកជើង ពាក់បេរ៉េ ពណ៌ខៀវទឹកប៊ិច ហើយកន្សែងរុំក ( ហ្វូឡា ) មានពណ៌ខៀវទឹកប៊ិច ហើយម៉ូត និងគុណភាព ក្រណាត់ដូចគ្នា ។

ខ_ <u>ឯកសណ្ឋានថ្នាក់ឧសេនីយ៍</u> : ឯកសណ្ឋានទាំងអស់ដូចគ្នាថ្នាក់ ឧត្ដមសេនីយ៍ ខុសគ្នាលើចំណុចមួយចំនួនដែលកំណត់សំរាប់ថ្នាក់វរសេនីយ៍ដូចខាងក្រោម ÷

-ហាមមួកកាស្កេត និងមួកហ្សិកគី ប៉ាក់ស្លឹកទេសឱន មុកចន្លោះកណ្ដាលមួកសង្ខាង ៤ ស.ម

-អាវកុដ ស ប៉ាក់លើ កអាវ និងប៉ានលើថ្នេរ ចុងដៃអាវ ពណ៌ទឹកប្រាក់

-ខោក្នុងឯកសណ្ឋានលេខ ១ ឆ្នូតតាមថ្នេរខោ ពណ៌ក្រហម ពីរដូចគ្នា ឧត្ដមសេនីយ៍ដែរ តែទទឹងឆ្នូតនិមួយៗ ប្រវែង ០១ ស.ម ។

-ខ្សែរំយោល ដូចឧត្ដមសេនីយ៍ គឺវេញចូលគ្នា ៣ ធ្លុង តែតូចជាងថ្នាក់ ឧត្ដមសេនីយ៍បន្តិច

គ_ <u>ឯកសណ្ឋានថ្នាក់អនុសេនីយ៍</u> : ឯកសណ្ឋានទាំងអស់ ដូចថ្នាក់ឧត្ដមសេនីយ៍ដែរ តែខុសគ្នាលើចំណុចមួយចំនួនដែលបានកំណត់សំរាប់ថ្នាក់ អនុសេនីយ៍ ដូចខាងក្រោម ÷

-ហាមមួកកាស្កេត និងមួកហ្សិកគី គ្មានប៉ានស្លឹកទេសឱនទេ [illegible]ហាមមួក មានឆ្នូត នៅតាមចុងហាមមួក ប្រវែងទទឹងឆ្នូត ចំនួន ៦ ម.ម ពណ៌មាស ។

-គ្មានប៉ាក់ នៅកអាវ កុដស និងប៉ាក់លើថ្នេរដៃអាវទាំងអស់

www.pheakdeylaw.com

-ខោងឯកសណ្ឋានលេខ១ ឆ្នូតតាមថ្នេរខោ ពណ៌ក្រហម មានតែមួយ ទទឹងឆ្នូតប្រវែង ២ ស.ម

-ខ្សែរក្រវាត់ដូចថ្នាក់វរសេនីយ៍ដែរ

ឃ_ **ចំពោះថ្នាក់នាយទាហានរង និងពលទាហាន** :

ក្នុងពេលណាចាំបាច់ ដែលក្រសួងការពារជាតិ និងអគ្គសេនាធិការ ពិនិត្យឃើញថា : ត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស ឬ ក្នុងពិធីការជាតិធំៗ នាយទាហានរង និងពលទាហាន អាចមានឯកសណ្ឋានធំលេខ ២ ឬលេខ៣ ដែរ ។ ចំពោះឯកសណ្ឋានទាំងនោះ ដូចថ្នាក់អនុសេនីយ៍ តែមួកកាស្កេតគ្មានក្បាច់ខ្សែសឹង ឆ្នូតអ្វីទាំងអស់ ។

ចំពោះនាយទាហាន និងពលទាហាន ការកំណត់ឯកសណ្ឋាន មានតែឯកសណ្ឋានការងារទេ ហើយឯកសណ្ឋានដូចថ្នាក់អនុសេនីយ៍ តែមួកកាស្កេត និងមួកហ្សៀកកី គ្មានប៉ាក់ ឬ ចំអ្វីទាំងអស់ ។

ខ_ **ឯកសណ្ឋានកងកិត្តិយស** : ( **កងម៉ូតូ** )

សំរាប់ពាក់ក្នុងពិធីដង្ហែរក្បួនការពារ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អាវធំ ( **ទាវី** ) ក្រណាត់តេទ្រ្កាល ពណ៌ប្រផេះ និងខោកាត់ដូចខោជំនាញ ពណ៌ត្រែអ៊ី ។

-មួកស៊ូកាស ពណ៌ទឹកប៊ិច ឬមួកបើកម៉ូតូ ស្បែកជើងធ្វើពីស្បែក កវែង ពណ៌ខ្មៅ ចងខ្សែកន្សែងក(ហ្វូឡា) ពណ៌ និងទំហំដូចខាងលើ ព្រមទាំងពាក់ស្រោមដៃ ពណ៌ស ខ្សែកញ្ចែ ពណ៌លឿង ។

-ខ្សែក្រវាត់ធំ ធ្វើពីស្បែក ពណ៌ស ដែលមានរូបសញ្ញា កងរាជអាវុធហត្ថ ដូចខាងក្រោម ៖

មាត្រា ២ ._ ត្រូវរៀបចំផ្លាកឈ្មោះ និង សក្តិ កងរាជអាវុធហត្ថ ដូចខាងក្រោម ៖

ក ផ្លាកឈ្មោះ : ធ្វើពីក្រណាត់ ផ្ទៃពណ៌ទឹកប៊ិច រាងបួនជ្រុងទ្រវែង មានបណ្តោយប្រវែង ១២ ស.ម. ទទឹងប្រវែង ២ ស.ម ដេរភ្ជាប់ខាងលើគំរបហោប៉ៅអាវស្តាំ ។

-ផ្លាកឈ្មោះប៉ាក់ជាអក្សរជាតិ អក្សរមូល ពណ៌ស បញ្ឈរ ដែលមានទំហំ ១.៥០ស.ម ខាងមុខអក្សរឈ្មោះ ប៉ាក់អក្សរកាត់ តាមឋានន្តរសក្តិ ឧត្តមសេនីយ៍ សរសេរអក្សរ ( **ឧ** ) វរសេនីយ៍ ( ** វ** ) អនុសេនីយ៍ ( **អ** ) នាយចំណោង ( **ន.ច** ) ព្រិន្ទបាល ( **ព្រ** ) ពលបាលទោ ( **ព** ) និងពលទាហានប៉ាក់តែឈ្មោះ ។

-ដោយឡែកផ្លាកឈ្មោះ សំរាប់ឯកសណ្ឋានលេខ ២ ដូចផ្លាកទ័ពជើងគោក

ខ_ **សក្តិ** : សក្តិកងរាជអាវុធហត្ថ យកគំរូដូចទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ហើយបានកំណត់ដូចខាងក្រោម ៖

-សក្តិសំរាប់ពាក់លើឯកសណ្ឋានលេខ ១ ( **អាវកុដស** ) ដូចទ័ពជើងគោក

www.pheakdeylaw.com

-សំរាប់ពាក់លើឯកសណ្ឋានលេខ ២_៥ ( អាវវីរ៉ី ផលរឺឯកសណ្ឋានធំមោញ្ញ ) ទំហំខ្នាតតូចទ័ពជើងគោកតែប្លុងស័ក្តិ ពណ៌ទឹកប៊ិច ។

-សក្តិសំរាប់ឯកសណ្ឋានប្រយុទ្ធតូចទ័ពជើងគោក

គ_ <u>សញ្ញាសំគាល់លើ ករអាវ</u> : ពាក់ដូចទ័ពជើងគោក

មាត្រា ៣ ._ ត្រូវប្រើ ផ្លាកសញ្ញា និងទង់កងរាជអាវុធហត្ថ ។

ក_ <u>ផ្លាកសញ្ញាកងរាជអាវុធហត្ថ សំរាប់ដាក់តាមក្លោងទ្វារបន្ទាយ និងពាក់លើហោប៉ៅ</u> :

-ផ្លាកសញ្ញាកងរាជអាវុធហត្ថ សំរាប់ដាក់តាមក្លោងទ្វារបន្ទាយកងឯកភាព កងរាជអាវុធហត្ថ និង សំរាប់ពាក់លើហោប៉ៅអាវខាងឆ្វេង កំពស់ ៨ស.ម មានម្ជុលខ្ទាស់ដាក់ខាងក្រោយពីលើចុះក្រោមតាមផ្ទៃព្រះខ័ន្ធ ។ ផ្លាកសញ្ញានេះ មានរូបភាព និង ម៉ូត ដូចខាងក្រោម ÷

-ផ្លាកសញ្ញាកងមួក ធ្វើពីដែក ក្រូម ឬ ដែកអ៊ីណុក ដែលមានវិជ្ជមាត្រ រង្វង់ក្រៅ មានប្រវែង ៧ ស.ម និងវិជ្ជមាត្រ រង្វង់ក្នុង មានប្រវែង ៥.៦ ស.ម ។

<u>ផ្នែកទី១</u> : ផ្នែកខាងក្នុងរង្វង់មាន :

-ផ្នែកខាងលើ និងខាងក្រោម ពណ៌ទឹកប៊ិចប្រវែង ១,៤ ស.ម និងកណ្តាល ពណ៌ក្រហម ប្រវែង ២,៨ ស.ម ។

-ចំខ្សែវិជ្ជមាត្រ រង្វង់ក្នុង ( តូច ) មានគ្រឿងសញ្ញាព្រះខ័ន្ធ ផ្ទៃពណ៌ស ដងពណ៌លឿងតាត់ ដាក់បញ្ឈរតំណាងអោយអ្នកការពារច្បាប់ ។

-នៅសង្ខាងអមផ្ទៃព្រះខ័ន្ធ មានតារិកអក្សរកាត់ពីរតួ ពណ៌ស គឺ ( ក.អ ) កំពស់ ២.៣ ស.ម តំណាងអង្គភាព កងរាជអាវុធហត្ថ ។

-នៅជុំព្រះខ័ន្ធ មានរូបលំពែង ពណ៌លឿង តំណាងអោយកងទ័ពជើងគោក

-នៅលើដង ខាងក្រោមលំពែង មានសង្ខាងមានរូបស្លាបសត្វ ដែលមានស្លាបម្ខាងៗ ១៧ តំណាងអោយកងទ័ពអាកាស ពណ៌មាស ។

<u>ផ្នែកទី២</u> : ផ្នែកខាងក្រៅរង្វង់មាន :

-នៅចុងខាងក្រោមដងព្រះខ័ន្ធ មានរូបយុថ្កា ពណ៌ខៀវ និងខ្សែរ័ន្ធយុថ្កា ពណ៌ស តំណាងអោយកងទ័ពជើងទឹក ។

-ផ្នែកខាងក្រៅ ក្នុងរង្វង់កណ្តាល អមសង្ខាង មានកួរស្រូវ ( ម្ខាងៗមាន៧ថ្នាក់ ) រំលេចដោយពណ៌មាសតំណាងអោយផលកសិកម្ម ។

-ខាងក្រោមដងព្រះខ័ន្ធ មានដាក់ខ្សែបូ ពណ៌ទឹកប៊ិច សំរាប់សរសេរ កងរាជអាវុធហត្ថម្នាក់ៗពាក់កាប់ផ្លាក ។

www.pheakdeylaw.com

-ផ្នែកខាងលើចុងព្រះខ័ន្ធ មានចារឹកអក្សរ(**កងរាជអាវុធហត្ថ**) ពណ៌ទឹកប៊ិច កំពស់០,៥ ស.ម។

**ខ_ <u>ផ្លាកសញ្ញាកងរាជអាវុធហត្ថ សំរាប់ដាក់លើដៃអាវ</u> :**

ផ្លាកសញ្ញាធ្វើពីក្រណាត់ ពោះគុម្ភ ឬ ក៉ាក់ សំរាប់ដេរភ្ជាប់លើដៃអាវឆ្វេង ឃ្លាតពីថ្នេរស្មាប្រវែង ៥ស.ម រួមមាន :

១-ផ្លាកសញ្ញាអង្គភាព កងរាជអាវុធហត្ថ សរសេរអក្សរកាត់ ( **អ.ហ** ) សំរាប់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ( រូបភាព និងទំហំ ដូចក្បាច់ដាក់លើពោកជើងឆ្វេង ធ្វើពីលោហធាតុ ) ។

២-ផ្លាកសញ្ញាសំគាល់កងឯកភាព ចល័ត មានរូបភាព និង ម៉ូត ដូចខាងលើ ( ១ ) ខុសត្រង់អក្សរ ( **ច.ល** ) សំរាប់កងឯកភាព ចល័ត ។

៣-ផ្លាកសញ្ញាសំរាប់ កងឯកភាព ខេត្ត-ក្រុង មានរូបភាព និង ម៉ូត ដូចខាងលើ (១) ខុសត្រង់សរសេរអក្សរ (**ខ . ក**) ។

៤-ផ្លាកសញ្ញាសំរាប់ កងឯកភាពតម្រួតយោធា មានរូបភាព និងម៉ូតូ ដូចខាងលើ (១) ខុសត្រង់សរសេរអក្សរ ( **ត . យ** ) ។

៥-ផ្លាកសញ្ញាសំរាប់កងភាពសាលា មានរូបភាព និង ខ្នាតដូចខាងលើ ( ១ ) ខុសត្រង់សរសេរអក្សរ ( ***ស.ល*** ) ។

**គ_ផ្លាកសញ្ញាបិទយានយន្ត និងគ្រឿងចក្រ :**

យានយន្ត និងគ្រឿងចក្រគ្រប់ប្រភេទរបស់កងរាជអាវុធហត្ថ ត្រូវដាក់ផ្លាកសញ្ញាសំរាប់សំគាល់យានយន្ត និងគ្រឿងចក្ររួមមាន ÷

១-ខ្នាតតូច សំរាប់ ម៉ូត ។

២-ខ្នាតមធ្យម សំរាប់ រថយន្តទេសចរ ។

៣-ខ្នាតធំ សំរាប់ រថយន្តធំ រថពាសដែក និងនាវាចរ ។

-នៅខាងក្រោមផ្លាកមូល សរសេរអក្សរឡាតាំង ( GENDARMERIE ) អក្សរ ពណ៌ស ទំហំ២/៣ នៃអក្សរកងរាជអាវុធហត្ថ ផ្នែកខាងលើផ្លាកមូល សរសេរឈ្មោះកងឯកភាព កងរាជអាវុធហត្ថដូចជា : ខេត្តបាត់ដំបងសរសេរតែអក្សរ ( បាត់ដំបង ) វរសេនាតូច រថពាសដែក សរសេរតែអក្សរ ( រថពាសដែក ) ។

**<u>រូបភាព និង ម៉ូត</u>** .......... ..........

**១ ម៉ូត** : ផ្លាកសញ្ញារាងមូល មានរូបភាព និង ម៉ូត ដូចខាងលើ ( ផ្លាកសញ្ញាកងរាជអាវុធហត្ថដាក់លើពោកជើងសំរាប់ពិធីភ្ជាប់លើតួ ម៉ូតូ ។

-មានវិជ្ជមាត្រ រង្វង់ក្រៅ ប្រវែង ១០ ស.ម និងវិជ្ជមាត្រ រង្វង់ក្នុង ប្រវែង ៨ ស.ម

www.pheakdeylaw.com

២_**<u>រថយន្តទេសចរណ៍</u>** : ផ្លាកសញ្ញារាងមូល មានរូបភាព និង ម៉ូត ដូចខាងលើតំរាបបិទភ្ជាប់ចំកណ្ដាលើគំរបម៉ាស៊ីន និងនៅលើទ្វារទាំងសង្ខាង ។

-មានវិជ្ជមាត្រ រង្វង់ក្រៅ ប្រវែង ៥០ ស.ម និងវិជ្ជមាត្រ រង្វង់មូលក្នុងប្រវែង ៣២ ស.ម

៣_**<u>រថយន្តធំ រថពាសដែក នាវា</u>** : ផ្លាកសញ្ញាមានរាងមូល មានរូបភាព និង ម៉ូត ដូចខាងលើតំរាប់បិទលើម៉ាស៊ីន និងទ្វារមុខទាំងសង្ខាង ។

-មានវិជ្ជមាត្រ រង្វង់ក្រៅ ប្រវែង ៥០ ស.ម និងវិជ្ជមាត្រ រង្វង់មូលក្នុង ប្រវែង ៥០ ស.ម

-ផ្លាកសញ្ញាទាំងបីប្រភេទខាងលើនេះ ត្រូវដាក់ទៅតាមផ្លាកសញ្ញា កងជំនាញរបស់ខ្លួន

ឃ_**<u>ទង់សំរាប់សំគាល់អង្គភាព កងរាជអាវុធហត្ថ</u>** :

១_**<u>ទង់សំរាប់ទីបញ្ជាការ</u>** : យកតាមគំរូទង់ជាតិ ព្រះរាជាណាចក្រកម្ពុជា ប្រាសាទអង្គរវត្ត កំពូល ៣ មានបណ្ដោយ ១.៨០ម៉ែត្រ ទទឹង ១.៣៥ ម៉ែត្រ ដងទង់ប្រវែង ២.៨០ម៉ែត្រ នៅជ្រុងខាងដើម ផ្នែកខាងលើមានរូបផ្លាកសញ្ញា កងរាជអាវុធហត្ថ ពណ៌មាស ឈ្មោះកងរាជអាវុធហត្ថ កំពស់អក្សរ ០.១០ ម៉ែត្រ នៅកណ្ដាលដងទង់ស្រួច ខាងលើផ្លាកម្ដុំរូបអុជ ពណ៌មាស និងខាងក្រោម មានផ្លាកសញ្ញា កងរាជអាវុធហត្ថខាងក្រោម ធ្វើពីលោហធាតុ ពណ៌មាស នៅកណ្ដាលដងទង់ មានរំយោល ពីរ ពណ៌មាស រំយោលមួយប្រវែង១ម៉ែត្រ មួយទៀតប្រវែង ១.២៥ម៉ែត្រ ធ្វើពីក្រណាត់នីឡុង ពណ៌ទឹកមាស ជុំវិញទង់លើជ្រុងទាំងបី មានរំយោល ពណ៌មាស ប្រវែង ០.១០ ម៉ែត្រ ។

២_**<u>ទង់ជ័យសំរាប់សំគាល់ តាមកងឯកភាពចំណុះ</u>** : រូបភាពដូចគ្នា តែខុសត្រង់ :

-បណ្ដោយប្រវែង ១.៧០ម៉ែត្រ ទទឹង ១.២៥ម៉ែត្រ ទង់ប្រវែង ២.៥៥ ម៉ែត្រ

-នៅជ្រុងខាងដើមផ្នែកខាងលើ មានផ្លាកសញ្ញា ពណ៌មាស សំរាប់អង្គភាព មានវិជ្ជមាត្រ ០.២៥ ស.ម ។

-នៅខាងក្រោមប្រាសាទ សរសេរអក្សរ ពណ៌មាស ឈ្មោះកងឯកភាព មានកំពស់ ១០ស.ម

៣_**<u>ទង់រាងត្រីកោណ</u>** : សំរាប់ដាក់លើ ម៉ូតូ រថយន្ត រថពាសដែក និង នាវា

**<u>ទំហំ</u>**

-រាងត្រីកោណ បាត ២០ស.ម កំពស់ ៣០ស.ម រូបភាព ពណ៌ រត់តាមបន្ទាត់ បាតទង់ខាងលើ និងខាងក្រោម ប្រវែង ៥ស.ម មានពណ៌ខៀវ កណ្ដាល ១០ស.ម ពណ៌ក្រហម នៅចំកណ្ដាលដាក់ផ្លាកកងឯកភាព ។

មាត្រា ៤ ._ ត្រូវបានកំណត់សំភារះ បំពាក់នៃគ្រឿងរួមផ្សំរបស់ឯកសណ្ឋាន កងរាជអាវុធហត្ថ ដូចខាងក្រោម ៖

ក_ **<u>មួកដែក និងខ្សែនាប់ក្លូច សំរាប់ធ្វើការចោរជំនាញ</u>** :

-មួកខ្សែនាប់ធ្វើពីស្បែក ពណ៌ទឹកប៊ិច ជុំវិញមានឆ្នូត ពណ៌ស ទំហំ ទទឹង ៤ស.ម ខាងមុខមានដាក់ព្រះសង្ហារខ្នាតធំ ធ្វើពីលោហធាតុ ពណ៌មាស នៅសង្ខាងសរសេរអក្សរ (ក.ហ) ពណ៌មាស មានកំពស់ ៤ ស.ម ។

ខ_ខ្សែកញ្ចែ : ខ្សែកញ្ចែ ធ្វើពីនីឡុង ពណ៌មាស វេញចូលគ្នា ៤ ធ្លុង ប្រវែង ៥០ ស.ម ពាក់ក្នុងប៉ូលេស្មាខាងស្តាំបន្ទាប់មកខ្ទាស់ខ្សែពីរ ប្រវែង ២០ស.ម ហើយដាក់កញ្ចែក្នុងហោប៉ៅស្តាំ ។

គ_ខ្សែក្រវ៉ាត់ធំពាក់ឈៀង : ( សាំខ្សែរ៉ូន )

-ខ្សែក្រវ៉ាត់ធំ ( សាំងវេរ៉ុង ) ធ្វើពីនីឡុង ពណ៌ស និងក្បាលក្រវ៉ាត់ធ្វើពីស្បែក ស ទំហំ ៦ ស.ម និងមានខ្សែពាក់ឆៀង ៣.៥ ស.ម បណ្តោយប្រវែង ១២០ ស.ម ពាក់ឆៀងក្នុងប៉ូលេស្តាំ ។

ឃ_ប៉ាន់ដៃ : ( ប្រាសសា )

-ប៉ាន់ដៃធ្វើអំពីស្បែក ផ្ទៃពណ៌ខ្មៅ សំរាប់ពាក់លើដៃអាវឆ្វេង ព័ទ្ធជុំវិញដៃអាវ ទទឹងប្រវែង ១១ ស.ម និងបណ្តោយ ៤០ ស.ម មានបន្ទាប់ពាក់លើប៉ូលេស្មាខាងឆ្វេង ប្រវែង ១៥ ស.ម ។

ប៉ាន់ដៃនេះមានពីរប្រភេទ :

-ចំណេញអក្សរសរសេរអក្សរម្ជុល (គ.យ) និង (ស.ហ) ធ្វើពីស្បែកពណ៌ស មានកំពស់ ៤ស.ម ដាក់ចំពីខាងលើប៉ាន់ដៃ ។

ង_ស្រោមដៃ ស :

ស្រោមដៃនីឡុង ពណ៌ស មួយសំរាប់ កខ្លី មួយសំរាប់ កវែង ។

ច_ខ្សែក្រវ៉ាត់ធំ សំរាប់បើកម៉ូតូ : ( កងកិត្តិយស )

-ខ្សែក្រវ៉ាត់ធំ ធ្វើពីស្បែក ពណ៌ស រាងពងក្រពើ ក្បាលខ្សែក្រវ៉ាត់រាងចុងស្រួច ប្រវែង ៨ស.ម តែចំកណ្តាលរាងពងក្រពើ ដូចរូបផ្លាកសញ្ញា កងរាជអាវុធហត្ថ ។

+មានវិជ្ជមាត្រ រង្វង់ក្រៅ ប្រវែង ២៥ ស.ម ។

+មានវិជ្ជមាត្រ រង្វង់ក្នុង ប្រវែង ២០ ស.ម ។

+ចន្លោះប្រវែង ២.៥ ស.ម ។

ឆ_ ប័ណ្ណសំគាល់របស់កងកម្លាំង កងរាជអាវុធហត្ថ :

ប័ណ្ណនេះមានបណ្តោយប្រវែង ១០ ស.ម និងទទឹង ០.៧ ស.ម ។

១_ផ្នែកខាងមុខ : បន្ទាត់ផ្ចិតក្រៅ ០.៤ ស.ម ក្នុង ០.៣ស.ម មានរូបសញ្ញា អង្គភាពពីខាងលើចារិកអក្សរព្រះរាជាណាចក្រកម្ពុជា ពីខាងក្រោមដាក់ ជាតិ សាសនា ព្រះមហាក្សត្រ ហើយមានសរសេរបន្តបន្ទាប់ដូចខាងក្រោម ៖

* នៅជ្រុងខាងលើ ហើយខាងឆ្វេង :

-ក្រសួងការពារជាតិ

-កងរាជអាវុធហត្ថ

-ប័ណ្ណសំគាល់លេខ ..................

* **<u>នៅចំកណ្ដាល</u> :**

-នាម និងគោត្តនាម

-ឋានន្តរសក្តិ

-តួនាទី ឬ មុខតំណែង ........................

-កងឯកភាព

-ការជូនដំណើរដល់អាជ្ញាធរស៊ីវិល ឬ យោធា ជួយសំរួលដល់ភារកិច្ចកងរាជអាវុធហត្ថ

-អនុញ្ញាតអោយប្រើអាវុធ ក្នុងឯកសណ្ឋានយោធា និងស៊ីវិល រូបភាពអង្គភាព ដាក់ក្រោមអក្សរ ក្រសួងការពារជាតិ ។

២_ផ្នែកខាងក្រោយ ជ្រុងខាងលើខាងឆ្វេង មានរូបភាពសញ្ញាមង់ជាតិ ដែលមានទទឹង ១.៥ ស.ម បញ្ឈិតកែងខាងឆ្វេង ខាងស្តាំក្នុងបន្ទាត់បួនជ្រុង សំរាប់បិទរូបថត ទំហំ ៤ × ៦ ខាងឆ្វេង ដាក់កណ្ដាលរូបថតសរសេរអក្សរស្នាមមេដៃស្តាំខាងក្រោម ចំកណ្ដាល សរសេរភិនភាគ ខាងក្រោមទៀត កំពស់_ សក់ _ ថ្ពាល់ _ មុខ និងស្លាកស្នាមខាងក្រោមទៀត ភ្នំពេញ , ថ្ងៃទី ......ខែ........ ឆ្នាំ ........ ( រូបភាពជូនភ្ជាប់មកជាមួយ ) ។

**មាត្រា ៥ ._** ជនណាក្លែងបន្លំដោយស្លៀកឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងប្រើប្រាស់ដូចមានចែងក្នុងមាត្រា១ ដល់មាត្រា ៥ ដើម្បីបន្លំខ្លួនធ្វើជាកងរាជអាវុធហត្ថ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៦ ._** បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារពាក់ព័ន្ធ ហើយផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ ._** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ និងគ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

***

www.pheakdeylaw.com